ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ថ្នល់ដាច់

## រយៈពេល ០៣ឆ្នាំ
## ( ២០១៨ - ២០២១ )

ឈ្មោះសហគមន៍នេសាទ ៖ ថ្នល់ដាច់
ទីស្នាក់ការ ៖ ភូមិថ្នល់ដាច់
ឃុំ ៖ ជានរុន
ស្រុក ៖ សូទ្រនិគម
ខេត្ត ៖ សៀមរាប

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ថ្នល់ដាច់

## រយៈពេល ០៣ឆ្នាំ
## (២០១៨ - ២០២១)

ឈ្មោះសហគមន៍នេសាទ ៖ ថ្នល់ដាច់
ទីស្នាក់ការ ៖ ភូមិថ្នល់ដាច់
ឃុំ ៖ ដានរុន
ស្រុក ៖ សូទ្រនិគម
ខេត្ត ៖ សៀមរាប

# មាតិកា


**១. ស្ថានភាពទូទៅ** ........................ ១

**២. អំពីប្រជាសាស្ត្រ និងសេដ្ឋកិច្ចសង្គម** ........................ ១

ក. ប្រជាពលរដ្ឋ ........................ ១

ខ. មុខរបរ ........................ ២

**៣. កន្លែងនេសាទ និងធនធានជលផលដែលមាននៅក្នុងកន្លែងនេសាទសហគមន៍** ........................ ៣

ក. ទីតាំង ........................ ៣

ខ. ដែននេសាទ ........................ ៣

ខ.១.បឹង ........................ ៣

ខ.២.ត្រពាំង ........................ ៣

ខ.៣.ផ្ទៃដីផ្សេងៗ ........................ ៤

គ. តំបន់ដែលមានលទ្ធភាពអាចបង្កើតកន្លែងអភិរក្ស ........................ ៥

ឃ. ធនធានជលផល ........................ ៥

ឃ.១.ប្រភេទត្រី ........................ ៥

ឃ.២.ប្រភេទវារីសត្វ ........................ ៥

ឃ.៣.ប្រភេទបក្សីទឹក ........................ ៦

ឃ.៤.ប្រភេទរុក្ខជាតិព្រៃលិចទឹក និងវារីរុក្ខជាតិ ........................ ៦

**៤. ការធ្វើនេសាទ** ........................ ៦

ក. អ្នកនេសាទ ........................ ៦

ខ. ឧបករណ៍នេសាទ ........................ ៦

គ. ការប៉ាន់ប្រមាណផលនេសាទចាប់បានប្រចាំឆ្នាំ ........................ ៧

**៥. ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍** ........................ ៨

ក. ទស្សនៈវិស័យ ........................ ៨

ខ. គោលបំណង ........................ ៨

គ. ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ........................ ៨

គ.១. ផែនការប្រើប្រាស់ឧបករណ៍នេសាទ ........................ ៨

គ.២. ផែនការកែលំអដែននេសាទ ........................ ៩

គ.៣. ផែនការរៀបចំកន្លែងអភិរក្ស ........................ ៩

គ.៤. ផែនការគ្រប់គ្រងនាទីព្រៃលិចទឹក ........................ ១០

គ.៥. ផែនការអភិវឌ្ឍន៍វារីវប្បកម្ម ........................ ១១

គ.៦. ផែនការថវិកា ទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍ ........................ ១២

គ.៧. ផែនការសកម្មភាពអភិវឌ្ឍន៍ ឃុំ ........................................ ១២
ឃ. យុទ្ធសាស្ត្រ ........................................ ១៨

**៦. ឧបសម្ព័ន្ធ**

ឧបសម្ព័ន្ធ: តារាងសង្ខេបផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ឆ្នាំ ២០១៨ ដល់ ២០២០
ឧបសម្ព័ន្ធ: តារាងកម្មវិធីការងារឆ្នាំ ២០១៨ ដល់ ២០២០

# ផែនការគ្រប់គ្រង
# តំបន់នេសាទសហគមន៍ ថ្នល់ដាច់

## ១. ស្ថានភាពទូទៅ

បន្ទាប់ពីការកែទម្រង់វិស័យជលផល របស់រាជរដ្ឋាភិបាល នាឆ្នាំ ២០០០ កន្លងមក រដ្ឋបាលជលផលបានរៀបចំការគ្រប់គ្រងធនធានធម្មជាតិ តាមបែបសហគមន៍ ដើម្បីឲ្យស្របជាមួយគោលនយោបាយវិមជ្ឈការ និងសហវិមជ្ឈការ ដែលជាយុទ្ធសាស្ត្រចតុកោណ របស់រាជរដ្ឋាភិបាល បានផ្តោតលើការកាត់បន្ថយភាពក្រីក្រ ដោយបានផ្ទេរសិទ្ធិអំណាចដល់ប្រជាពលរដ្ឋរស់នៅក្នុងតំបន់ជនបទ ដើម្បីចូលរួមគ្រប់គ្រងធនធានជលផលនៅក្នុងមូលដ្ឋានរបស់ខ្លួនប្រកបដោយចីរភាព និងសមធម៌ ក្នុងគោលបំណងទទួលបានផលប្រយោជន៍ធ្វើឲ្យធនធានជលផលប្រសើរឡើងក្នុងមូលដ្ឋានរបស់ខ្លួន ។

សហគមន៍នេសាទថ្នល់ដាច់ បានបង្កើតឡើងជាដំបូង ដោយមានការចូលរួមយ៉ាងច្រើនកុះករពីប្រជាពលរដ្ឋក្នុងឃុំជានរុន ដោយមានកិច្ចសហការរៀបចំពីអាជ្ញាធរមូលដ្ឋាន ជំនាញជលផល ព្រមទាំងមានការគាំទ្របច្ចេកទេសពីគម្រោងការចូលរួមគ្រប់គ្រងធនធានធម្មជាតិតំបន់បឹងទន្លេសាប តាមរយៈការធ្វើមហាសន្និបាត នៅឆ្នាំ ២០០០ ។ រហូតឆ្នាំ២០០៤ សហគមន៍ទទួលបានការគាំទ្រពីគម្រោងគ្រប់គ្រងបរិស្ថានបឹងទន្លេសាប ។ រហូតបច្ចុប្បន្នសហគមន៍នេសាទថ្នល់ដាច់មានរយៈពេល ៣ អាណត្តិ មកហើយ ហើយតាមអាណត្តិនីមួយៗ សហគមន៍បានរៀបចំបំពេញឯកសារ លក្ខន្តិកៈ កិច្ចព្រមព្រៀង បទបញ្ជាផ្ទៃក្នុង និងផែនការគ្រប់គ្រង ដើម្បីអនុវត្តន៍សកម្មភាពការងារក្នុងសហគមន៍បានជាប្រចាំ ។

សហគមន៍នេសាទថ្នល់ដាច់ មានទីតាំងស្ថិតនៅភូមិថ្នល់ដាច់ ឃុំជានរុន ស្រុកសូទ្រនិគម ខេត្តសៀមរាប ។ សហគមន៍មានសមាជិកសរុបចំនួន ៧២៥ គ្រួសារ ហើយបានចុះឈ្មោះជាសមាជិកភាពមានចំនួន ១.៣១៧ នាក់ ក្នុងនោះមានស្ត្រីចំនួន ៦៧៨ នាក់ ។ សហគមន៍មានរចនាសម្ព័ន្ធដឹកនាំដោយគណៈកម្មការចំនួន ១១នាក់ ក្នុងនោះមានស្ត្រីចំនួន ០១ នាក់ ។

បន្ទាប់ពីការរៀបចំរចនាសម្ព័ន្ធសហគមន៍រួចមក គណៈកម្មការសហគមន៍នេសាទថ្នល់ដាច់ បានដើរតួយ៉ាងសំខាន់ក្នុងការគ្រប់គ្រង និងអភិរក្សធនធានធម្មជាតិក្នុងដែននេសាទសហគមន៍យ៉ាងសកម្ម ។ មិនតែប៉ុណ្ណោះគណៈកម្មការបានចូលរួមសកម្មភាពអភិរក្សត្រីមេពូជ ការការពារនាទីព្រៃលិចទឹក និងពង្រឹងកិច្ចសហការទប់ស្កាត់ បង្ក្រាបបទល្មើសជលផលគ្រប់ប្រភេទ និងបង្កើនសកម្មភាពមុខរបរចិញ្ចឹមជីវិតបន្ថែម ដល់សមាជិកក្នុងសហគមន៍ ។

## ២. អំពីប្រជាសាស្ត្រ និង សេដ្ឋកិច្ច

### ក. ប្រជាពលរដ្ឋ

ឃុំជានរុនមានភូមិចំនួន ១៣ ភូមិ ក្នុងនោះមាន៖ ភូមិគោកឫស្សីជើង គោកឫស្សីត្បូង ត្រាវគៀត ថ្នល់ដាច់ ស្រម៉ធំ រុនត្បូង រុនជើង វាលបន្ទាត់បោះ សន្ទែ ធ្នង់ គោកចាន់ និងភូមិបេង ។ ដោយឡែកប្រជាពលរដ្ឋបានចូលជាសមាជិកសហគមន៍នេសាទមានចំនួន ០៥ភូមិ គឺ ភូមិគោកឫស្សីជើង គោកឫស្សីត្បូង ត្រាវគៀត ថ្នល់ដាច់ និងស្រម៉ធំ ។ រីឯភូមិដទៃទៀតមានទីតាំងភូមិសាស្ត្រ និងប្រជាពលរដ្ឋភាគច្រើនមានមុខរបរពុំពាក់ពន្ធ័នឹងតំបន់នេសាទ និងពុំបានចូលរួមជាសមាជិកសហគមន៍នេសាទ ។

ឃុំជានរុនមានប្រជាពលរដ្ឋសរុបចំនួន ២.៨៦៥ គ្រួសារ ដែលមានសមាជិកសរុបចំនួន ១៣.៤៥២ នាក់ ក្នុងនោះមានស្ត្រីចំនួន ៦.៩១៧ នាក់ (ស្ថិតិឃុំឆ្នាំ ២០១៨) ។ អំពីជនជាតិមានៈ ជនជាតិខ្មែរចំនួន ២.៨៧៨គ្រួសារ និងជនជាតិឥស្លាមចំនួន ០៤គ្រួសារ ។

ផ្អែកតាមស្ថិតិប្រជាពលរដ្ឋក្នុងឃុំបានបង្ហាញនូវកំណើនប្រជាពលរដ្ឋក្នុងឃុំទាំងមូល មានការកើនឡើងជារៀងរាល់ឆ្នាំ ។

សហគមន៍នេសាទថ្មល់ដាច់មានសមាជិកសរុបចំនួន ១.៣១៧ នាក់ ក្នុងនោះមានស្ត្រីចំនួន ៦៧៨ នាក់ ។

ក្នុងនោះមានៈ

- មានស្ត្រីមេម៉ាយចំនួន ១៥១ នាក់
- ជនពិការចំនួន ៤៣នាក់ ក្នុងនោះមានស្ត្រី ១៧ នាក់
- ចាស់ជរាចំនួន ១១០នាក់ ក្នុងនោះមានស្ត្រី ៦០ នាក់
- កុមារកំព្រាចំនួន ២០នាក់ ក្នុងនោះមានស្ត្រី០៩នាក់
- មានជំងឺរ៉ាំរ៉ៃចំនួន ១៨នាក់ ក្នុងនោះមានស្ត្រី ១១នាក់
- ប្រជាពលរដ្ឋក្នុងសហគមន៍ជាអ្នកកាន់សាសនាព្រះពុទ្ធចំនួន ៩៩,៦០ %
- អ្នកកាន់សាសនាឥស្លាមប្រមាណ ០,៤០ %

**កម្រិតវប្បធម៌ នៃសមាជិកសហគមន៍នេសាទថ្មល់ដាច់មានៈ**

- អ្នកមិនចេះអក្សរមានចំនួន ៤៧ នាក់ ក្នុងនោះមានស្ត្រី ២៥ នាក់
- កម្រិតថ្នាក់បឋមសិក្សាមានចំនួន ២៦៥ នាក់ ក្នុងនោះមានស្ត្រី ១១៤ នាក់
- កម្រិតថ្នាក់មធ្យមសិក្សាមានចំនួន ៦០២ នាក់ ក្នុងនោះមានស្ត្រី ២៩៦ នាក់
- កម្រិតថ្នាក់ឧត្តមសិក្សាមានចំនួន ៧២ នាក់ ក្នុងនោះមានស្ត្រី ៣៥ នាក់

## ខ. មុខរបរ

តាមការចុះអង្កេត និងការប្រមូលព័ត៌មានពីប្រជាពលរដ្ឋនៅក្នុងឃុំជានរុនបានបញ្ជាក់ថា សហគមន៍នេសាទថ្មល់ដាច់ មានប្រជាពលរដ្ឋសរុបចំនួន ៦៥% ដែលពឹងផ្អែកលើការនេសាទត្រី ការចិញ្ចឹមត្រី និងធ្វើស្រែចំការ រីឯស្ត្រីគ្រាន់តែជាអ្នកប្រកបមុខរបរបន្ទាប់បន្សំមានដូចជា កែច្នៃផលនេសាទ ផ្តល់ចំណីត្រី និងលក់ដូរជាដើម ។ ការគាំទ្រមុខរបរចិញ្ចឹមជីវិតដល់សមាជិកសហគមន៍នេសាទជាសកម្មភាពចំបង ដែលជួយពង្រីកមុខរបរដល់ប្រជានេសាទនៅក្នុងសហគមន៍ ជាពិសេសបានជួយកាត់បន្ថយសម្ពាធនៃការធ្វើអាជីវកម្មលើធនធានជលផលមួយកំរិត ។ កន្លងមករដ្ឋបាលជលផល និងអង្គការដៃគូអភិវឌ្ឍន៍នានា បានជួយបណ្តុះបណ្តាល អំពីបច្ចេកទេសការចិញ្ចឹមសត្វ ការចិញ្ចឹមត្រីជាលក្ខណៈគ្រួសារ ព្រមទាំងមុខរបរចិញ្ចឹមជីវិតផ្សេងៗទៀតជាច្រើន ដល់សមាជិកសហគមន៍នេសាទ ដើម្បីរួមចំណែកជួយលើកស្ទួយសេដ្ឋកិច្ចគ្រួសារឲ្យមានការរីកចំរើន ។ រហូតបច្ចុប្បន្ននៅក្នុងសហគមន៍នេសាទថ្មល់ដាច់ ប្រជាពលរដ្ឋមានស្ថានភាព នៃការចិញ្ចឹមជីវិត និងមុខរបរសំខាន់ៗ ដូចខាងក្រោមៈ

- ធ្វើនេសាទមានចំនួន ១០៤ គ្រួសារ
- ធ្វើស្រែមានចំនួន ៣៣៥ គ្រួសារ ផ្ទៃដីស្រែចំនួន ៣០៧ ហិកតា
- ធ្វើវារីវប្បកម្មមានចំនួន ១៥ គ្រួសារ ផ្ទៃដីស្រះចំនួន ០៥ ហិកតា
- ដាំបន្លែមានចំនួន ៥៩ គ្រួសារ ផ្ទៃដីចំនួន ០៤ ហិកតា
- ជាងផ្ទះមានចំនួន ០៧ គ្រួសារ
- ធ្វើចំការមានចំនួន ០៥ គ្រួសារ ផ្ទៃដីចំនួន ២០ ហិកតា
- ធ្វើសិប្បកម្មមានចំនួន ០៥ គ្រួសារ

- លក់ដូរមានចំនួន ៦១ គ្រួសារ
- កែច្នៃផលនេសាទ ០២ គ្រួសារ
- សាកអាគុយមានចំនួន ០១ គ្រួសារ
- ជាងកង់មានចំនួន ០៥ គ្រួសារ
- កាត់សក់មានចំនួន ០៥ គ្រួសារ
- ម៉ាស៊ីនកិនស្រូវមានចំនួន ១៣ គ្រួសារ
- ជួលមេក្រូមានចំនួន ០៦ គ្រួសារ

**៣. កន្លែងនេសាទ និងធនធានជលផលដែលមាននៅក្នុងកន្លែងនេសាទសហគមន៍**

**ក. ទីតាំង**

សហគមន៍នេសាទថ្នល់ដាច់មានទីតាំងស្នាក់ការស្ថិតនៅភូមិថ្នល់ដាច់ ឃុំជានរុន ស្រុកសូទ្រនិគម ។ កន្លែងនេសាទសហគមន៍មានផ្ទៃដីសរុបចំនួន ២.១៣៤ ហិកតា ដែលមាននិយាមកាដូចមានចែងនៅក្នុងកិច្ចព្រមព្រៀង ។

សហគមន៍នេសាទថ្នល់ដាច់មានព្រំប្រទល់ជាប់នឹង៖

- ខាងជើងទល់នឹងទំនប់ ៧៨
- ខាងត្បូងទល់នឹងសហគមន៍នេសាទព្រែកស្រម៉ោច (ឃុំកំពង់ឃ្លាំង)
- ខាងកើតទល់នឹងផ្លូវលេខ ២៦៥ (ផ្លូវចុះទៅកំពង់ឃ្លាំង)
- ខាងលិចទល់នឹងព្រែកជីក

**ខ. ដែននេសាទ**

កន្លែងនេសាទសហគមន៍ថ្នល់ដាច់មានវិសាលភាពជាប់មាត់ទន្លេសាប ដែលគ្រប់ដណ្តប់ដោយនាទីព្រៃលិចទឹក ព្រែក បឹង ត្រពាំង កន្លែងអភិរក្សពូជត្រី និងអន្លង់សំខាន់ៗមួយចំនួនដូចខាងក្រោម៖

**ខ.១. បឹង**

| ល.រ | ឈ្មោះបឹង | ផ្ទៃដី (ហ.ត) | រដូវនេសាទ |
|---|---|---|---|
| ១ | បឹងចំការឈូក | ១០៧ | ខែមករា ដល់ ខែធ្នូ |
| ២ | បឹងសំពាន់ | ២៣ | ខែមករា ដល់ ខែធ្នូ |

**ខ.២. ត្រពាំង**

| ល.រ | ឈ្មោះត្រពាំង | ផ្ទៃដី (ហ.ត) | រដូវនេសាទ |
|---|---|---|---|
| ១ | ត្រពាំងប្រឹស | ០,៩០ | ខែមករា ដល់ ខែធ្នូ |
| ២ | ត្រពាំងគោស្លាប់ | ០,៧០ | ខែសីហា ដល់ ខែមីនា |
| ៣ | ត្រពាំងកូនអក | ០,២០ | ខែមករា ដល់ ខែធ្នូ |
| ៤ | ត្រពាំងកាច់ស្នតូច | ០,៤២ | ខែមករា ដល់ ខែធ្នូ |
| ៥ | ត្រពាំងកាច់ស្នធំ | ១,៣៥ | ខែមករា ដល់ ខែធ្នូ |
| ៦ | ត្រពាំងថ្វាន់ | ០,៥២ | ខែមករា ដល់ ខែធ្នូ |
| ៧ | ត្រពាំងស្មោញ | ០,៤០ | ខែមករា ដល់ ខែធ្នូ |
| ៨ | ត្រពាំងថ្មលើ | ០,៥៤ | ខែកក្កដា ដល់ ខែមេសា |
| ៩ | ត្រពាំងត្នាត | ១,២៥ | ខែមករា ដល់ ខែធ្នូ |
| ១០ | ត្រពាំងថ្មតូច | ០,៤៥ | ខែកក្កដា ដល់ ខែមេសា |

| | | | |
|---|---|---|---|
| ១១ | ត្រពាំងចំរូង | ១,៥០ | ខែមករា ដល់ ខែធ្នូ |
| ១២ | ត្រពាំងចកពុល | ០,៥៥ | ខែកក្កដា ដល់ ខែមេសា |
| ១៣ | ត្រពាំងភ្លោះ | ០,២៥ | ខែកក្កដា ដល់ ខែមីនា |
| ១៤ | ត្រពាំងភ្លោះ១ | ០,២០ | ខែកក្កដា ដល់ ខែមីនា |
| ១៥ | ត្រពាំងរើរាម | ០,១៩ | ខែកក្កដា ដល់ ខែមីនា |
| ១៦ | ត្រពាំងរើរាម១ | ០,១៦ | ខែកក្កដា ដល់ ខែមីនា |
| ១៧ | ត្រពាំងថ្លាត | ២,០០ | ខែមករា ដល់ ខែធ្នូ |
| ១៨ | ត្រពាំងកំប្រុក | ០,១៥ | ខែមករា ដល់ ខែកុម្ភៈ |
| ១៩ | ត្រពាំងកន្ទរ | ០,៦៣ | ខែមករា ដល់ ខែកុម្ភៈ |
| ២០ | ត្រពាំងប្រក់ស្បូវ | ១,៤៣ | ខែមករា ដល់ ខែកុម្ភៈ |
| ២១ | ត្រពាំងតាជៀស | ០,៣០ | ខែកក្កដា ដល់ ខែមីនា |
| ២២ | ត្រពាំងតាដោក | ០,៦២ | ខែកក្កដា ដល់ ខែមីនា |
| ២៣ | ត្រពាំងតាស្រី (ព្រែកស្រម៉ោច) | ០,៤៨ | ខែសីហា ដល់ ខែមីនា |
| ២៤ | ថ្លុំប៉ី | ០,៣០ | ខែមករា ដល់ ខែកុម្ភៈ |
| ២៥ | កូតទ្រូ | ០,២៥ | ខែមករា ដល់ ខែកុម្ភៈ |
| ២៦ | អន្លង់ដេក | ០,២៤ | ខែមករា ដល់ ខែកុម្ភៈ |
| ២៧ | កាត់សក់ | ០,១០ | ខែមករា ដល់ ខែកុម្ភៈ |
| ២៨ | អន្លង់ខាំដៃ | ០,០៨ | ខែមករា ដល់ ខែកុម្ភៈ |
| ២៩ | តាទន់ | ០,០៨ | ខែមករា ដល់ ខែកុម្ភៈ |
| ៣០ | ស្វាអិល | ០,៤៤ | ខែមករា ដល់ ខែកុម្ភៈ |
| ៣១ | តាងួន | ០,០៨ | ខែមករា ដល់ ខែកុម្ភៈ |
| ៣២ | ប្រវឹករាល | ០,០៨ | ខែមករា ដល់ ខែកុម្ភៈ |
| ៣៣ | សុកអេវ | ០,០៨ | ខែមករា ដល់ ខែមីនា |
| ៣៤ | សំបកអូរម៉ាល់ | ០,០៦ | ខែមករា ដល់ ខែមីនា |
| ៣៥ | ត្រាស់ | ០,៥០ | ខែមករា ដល់ ខែមីនា |
| ៣៦ | ប្រឹសតូច | ០,៦០ | ខែមករា ដល់ ខែមីនា |

**ខ.៣. ផ្ទៃដីផ្សេងៗទៀត**

| ល.រ | ឈ្មោះថ្លុក | ផ្ទៃដី (ហ.ត) | រដូវនេសាទ |
|---|---|---|---|
| ១ | កន្លុកតាងួន | ០,២៨ | ខែមករា ដល់ ខែធ្នូ |
| ២ | ស្រះតាអ៊ិច | ០,២១ | ខែមករា ដល់ ខែធ្នូ |
| ៣ | ដីកសិកម្ម | ៥៨៩ | ខែមករា ដល់ ខែធ្នូ |
| ៤ | ព្រៃលិចទឹក | ៩២០ | ០៣ កន្លែង |
| ៥ | បឹង ព្រែក អូរ ត្រពាំង | ១៤៦ | ៣៧ កន្លែង |
| ៦ | ដីលំនៅដ្ឋាន | ១១ | ក្នុងសហគមន៍ |

កន្លែងនេសាទសហគមន៍ថ្នល់ដាច់ បានផ្តល់លក្ខណៈងាយស្រួលដល់ការរស់នៅ និងការធ្វើអាជីវកម្មនេសាទរបស់ប្រជាពលរដ្ឋនៅក្នុងសហគមន៍ ក៏ដូចជាអ្នកមកពីខាងក្រៅសហគមន៍ ជាពិសេសកន្លែងនេសាទសហគមន៍មានអំណោយផលល្អដល់ការរស់នៅរបស់ពពួកវារីសត្វ រុក្ខជាតិ ដែលជាចំណី និងជម្រកពងកូនរបស់មច្ឆជាតិ សត្វស្លាប និងសត្វល្មូនគ្រប់ប្រភេទ ។ម្យ៉ាងទៀតកន្លែងនេសាទសហគមន៍ថ្នល់ដាច់ បានតភ្ជាប់ជាមួយដៃព្រែកជាច្រើន ដែលទទួលរបបទឹកពីបឹងទន្លេសាប និងពីតំបន់ខ្ពង់រាប ចូលមកបំពេញ បឹង ត្រពាំង ថ្លុក និងដីទំនាបព្រៃលិចទឹក ក្នុងដែននេសាទសហគមន៍ ដែលបានផ្តល់ផលប្រយោជន៍យ៉ាងច្រើនដល់ដំណាំកសិកម្ម ។

**គ. តំបន់ដែលមានលទ្ធភាពអាចបង្កើតកន្លែងអភិរក្ស**

សហគមន៍នេសាទថ្នល់ដាច់ បានសម្រេចបង្កើតកន្លែងអភិរក្សចំនួន០១កន្លែង ដែលជាកន្លែងមានសក្តានុពលសម្រាប់អភិរក្សត្រីមេពូជ និងធនធានជលផលផ្សេងៗទៀត ។ កន្លែងអភិរក្សត្រូវបានធ្វើការគ្រប់គ្រងដោយគណៈកម្មការសហគមន៍នេសាទ មានដូចខាងក្រោម៖

| **ល.រ** | **ឈ្មោះបឹងដែលមានលទ្ធភាពបង្កើតកន្លែងអភិរក្ស** | **ផ្ទៃដី** (ហ.ត) | **ប្រវែង** |
|---|---|---|---|
| ១ | បឹងចំការឈូក | ១០៧ | |
| ២ | បឹងសំពាន់ | ២៣ | |

**ឃ. ធនធានជលផល**

ខេត្តសៀមរាបសំបូរទៅដោយធនធានធម្មជាតិដូចជា ស្ទឹង បឹងបួរ អាងទឹក ប្រឡាយជាច្រើន ដែលទទួលប្រភពទឹកពីតំបន់ខ្ពង់រាប ហើយហូរចាក់ទៅក្នុងបឹងទន្លេសាប ។ អំណោយផលទាំងនេះ អាចផ្តល់ទឹកសម្រាប់ ប្រើប្រាស់ ស្រោចស្រពដំណាំកសិកម្មក្នុងតំបន់នានាទូទាំងខេត្ត និងផ្តល់ដល់ការធ្វើចរាចរកកន្លែងពងកូន និងការរកចំណីរបស់មច្ឆជាតិទៀតផង ។ ក្រៅពីនេះធនធានជលផលបានដើរតួនាទីយ៉ាងសំខាន់ក្នុងការធានាសន្តិសុខស្បៀងដល់ការចិញ្ចឹមជីវិតរបស់ប្រជាពលរដ្ឋប្រចាំថ្ងៃ ។ តាមការចង្អុលបង្ហាញពីគណៈកម្មការសហគមន៍នេសាទថ្នល់ដាច់ បានឱ្យដឹងថា ពេលបច្ចុប្បន្នធនធានជលផលមានការថយចុះបន្តិច ដោយសារកត្តាប្រែប្រួលអាកាសធាតុ ការរាំងស្ងួត ទឹកជំនន់ ការកាប់ ទន្ទ្រានព្រៃលិចទឹក ដែលបណ្តាលឱ្យបឹង និងព្រែក រីងរាក់ ហើយធ្វើឲ្យប្រភេទត្រីមួយចំនួនបានបាត់បង់ពូជ ។

ឆ្លងតាមការអង្កេតរបស់ក្រុមការងារ និងគណៈកម្មការសហគមន៍នេសាទបានផ្តល់ទិន្នន័យធនធានជលផលក្នុងសហគមន៍នេសាទថ្នល់ដាច់មានដូចខាងក្រោម៖

**ឃ.១. ប្រភេទត្រី**

ឆ្លងតាមការសិក្សាស្រាវជ្រាវ និងការវាស់ស្ទង់ទិន្នផលត្រីចាប់បាន នៅក្នុងដែននេសាទសហគមន៍ថ្នល់ដាច់ មានជួបប្រទះប្រភេទត្រីជាច្រើនដូចជា៖ ត្រីរៀល ត្រីឆ្លាំង ត្រីកែស ត្រីកញ្ចុះ ត្រីអាចម៍កុក ត្រីឆ្ពែក ត្រីគ្រំ ត្រីឆ្កិន ត្រីកន្ធ្រប់ ត្រីប្រម៉ា ត្រីក្រសក់ ត្រីក្រាយ ត្រីក្រម៉ម ត្រីខ្នឹង ត្រីខ្លា ត្រីរ៉ស់ ត្រីឆ្តោ ត្រីអណ្តែង ត្រីឆ្ពួញ ត្រីចេកទុំ ត្រីឆ្តោក ត្រីកញ្ចុះក្តោង ត្រីក្រពត ត្រីចង្វា ត្រីដំរី ត្រីកំភ្លាញភ្លុក ត្រីកំភ្លាញស្រែ ត្រីផ្ទក់ ត្រីអណ្តាតឆ្កែ ត្រីឈ្វាត ត្រីក្រាញ់ ត្រីក្រុស ត្រីចន្លាស់ភ្លុក ត្រីសង្កត់ប្រាក់ ត្រីព្រួល ត្រីស្លាត ត្រីស្រកាក្តាម ត្រីកំភ្លៀវ ត្រីខ្នាន់ ត្រីដៀប ត្រីចង្វាមូល ត្រីលិញ ត្រីក្លាំងហាយ ។ល។

**ឃ.២. ប្រភេទវារីសត្វ**

ក្នុងសហគមន៍នេសាទថ្នល់ដាច់មានប្រភេទវារីសត្វដូចជា៖ ក្តាម ខ្យង ខ្ចៅ គ្រុំ លៀស អណ្តើក គន្ធាយ ពស់ កង្កែប ហ៊ីង គីង្គក់ អន្ទង់ ក្តាមទូក កន្ធេះឡង់ ក្រពើត្រី អន្សង ភេ សត្វស្វា សំពោច ។ល។

**ឃ.៣. ប្រភេទបក្សី**

នៅសហគមន៍នេសាទថ្នល់ដាច់មានប្រភេទបក្សីទឹកជាច្រើនប្រភេទដូចជា៖ ក្អែកទឹក សត្វក្រៀល សត្វទោម សត្វទុង សត្វប្រវឹក សត្វក្រសា សត្វកុកស សត្វមាន់ទឹក សត្វទាព្រៃ សត្វទាទឹក សត្វទុង សត្វស្មោញ សត្វសេក សត្វលលក សត្វចាប សត្វត្រយ៉ង សត្វនាលខ្សង សត្វត្រដក់ សត្វកំពីងដូង ។ល។

**ឃ.៤. ប្រភេទរុក្ខជាតិព្រៃលិចទឹក និងវារីរុក្ខជាតិ**

សហគមន៍នេសាទថ្នល់ដាច់ មានរុក្ខជាតិប្រភេទព្រៃលិចទឹក និងវារីរុក្ខជាតិដូចជា៖ ដើមរាំងទឹក ដើមតាអ្វរ ដើមអញ្ចាញ ដើមថ្ងាន់ ដើមកន្សែង ដើមបន្លាយួន ដើមស្អាចទឹក ដើមកណ្ដាប់ចង្កេរ ដើមរំដេញ ដើមបន្លាស្អិត ដើមច្រកែង ដើមភ្នំភ្លៀង ។ល។

**៤. ការធ្វើនេសាទ**

ការនេសាទជាមុខរបរសំខាន់ សម្រាប់ការចិញ្ចឹមជីវិតរបស់ប្រជាពលរដ្ឋក្នុងសហគមន៍នេសាទថ្នល់ដាច់ ហើយផលិតផលត្រីត្រូវបានផ្គត់ផ្គង់ សម្រាប់ម្ហូបអាហារក្នុងមូលដ្ឋានផ្ទាល់ និងដើម្បីទីផ្សារក្នុងស្រុក និងធ្វើពាណិជ្ជកម្មទៅក្រៅប្រទេសទៀតផង ដើម្បីរកប្រាក់ចំណូលដល់សេដ្ឋកិច្ចគ្រួសារ និងសង្គមជាតិ ។ រហូតបច្ចុប្បន្នមានប្រជាពលរដ្ឋភាគច្រើនក្នុងសហគមន៍ បានផ្ដោតយកចិត្តទុកដាក់លើការនេសាទត្រី ដោយបានប្រើប្រាស់ឧបករណ៍នេសាទជាលក្ខណៈគ្រួសារក្នុងការទាញយកផលនេសាទពីធម្មជាតិ ។ ចំពោះមុខនេះការនេសាទរបស់សមាជិកក្នុងសហគមន៍ និងអ្នកខាងក្រៅសហគមន៍ត្រូវបានអនុវត្តស្របតាមលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង និងស្ថិតក្នុងរង្វង់ព្រំប្រទល់ផែនទីកន្លែងនេសាទសហគមន៍ ជាពិសេសស្របតាមផែនការគ្រប់គ្រងរបស់សហគមន៍ ដែលបានរៀបចំសម្រាប់ឆ្នាំអាណត្តិនីមួយៗ ។ កន្លងមកទោះបីមានជនខិលខូច បានលួចប្រើឧបករណ៍នេសាទខុសច្បាប់ នៅកន្លែងនេសាទសហគមន៍ថ្នល់ដាច់ខ្លះៗក៏ពិតមែន តែកម្លាំងក្រុមល្បាត របស់គណៈកម្មការសហគមន៍បានសហការទប់ស្កាត់បានទាន់ពេលវេលា ដើម្បីរក្សាផលត្រីឲ្យមានកំណើនកើនឡើង ។

តាមការសិក្សា និងប្រមូលទិន្នន័យពីប្រជានេសាទក្នុងសហគមន៍ថ្នល់ដាច់ បានបង្ហាញពីស្ថិតិអ្នកដែលពាក់ព័ន្ធក្នុងការធ្វើអាជីវកម្មនេសាទ នៅកន្លែងនេសាទសហគមន៍ មានដូចខាងក្រោម៖

**ក. អ្នកនេសាទ**

អ្នកនេសាទជាសមាជិកសហគមន៍នេសាទមានចំនួន ៣៤៦ នាក់ ក្នុងនោះមានស្ត្រី ០៥នាក់

អ្នកនេសាទមិនមែនជាសមាជិកសហគមន៍ នៅក្នុងសហគមន៍មានចំនួន ៩៧១ នាក់

អ្នកនេសាទមកពីខាងក្រៅសហគមន៍មានប្រមាណ ៧៩នាក់ ក្នុងនោះមានស្ត្រី ០៥ នាក់ ក្នុង១ឆ្នាំ

**ខ. ឧបករណ៍នេសាទ**

នៅរដូវបើកនេសាទ ប្រជានេសាទនៅសហគមន៍នេសាទថ្នល់ដាច់ និងអ្នកខាងក្រៅសហគមន៍ តែងតែធ្វើនេសាទដោយប្រើប្រភេទឧបករណ៍នេសាទជាលក្ខណៈគ្រួសារមានដូចជា៖ លប មង សន្ទូច លបព្រៀង ឡើ លាន់ និងជុច ។ល។ គណៈកម្មការ និងសមាជិកសហគមន៍នេសាទថ្នល់ដាច់ បានធ្វើការប៉ាន់ប្រមាណពីតម្រូវការប្រភេទឧបករណ៍នេសាទដែលស្របតាមលក្ខន្តិកៈ បទបញ្ញាផ្ទៃក្នុង និងផែនការគ្រប់គ្រងរបស់សហគមន៍ ជាពិសេសគណៈកម្មការសហគមន៍នេសាទ បានសំណូមពរឲ្យសមត្ថកិច្ចជំនាញជលផល ធ្វើការផ្សព្វផ្សាយអំពីលិខិតបទដ្ឋានគតិយុត្តផ្សេងៗ ដែលពាក់ព័ន្ធនឹងវិស័យជលផលឲ្យបានច្រើនដង ដល់ប្រជាពលរដ្ឋក្នុងសហគមន៍នេសាទ និងអ្នកនេសាទខាងក្រៅ ជាពិសេសលើការប្រើប្រភេទឧបករណ៍នេសាទដែលច្បាប់ហាមឃាត់មានដូចជា៖ ឧបករណ៍ឆក់ត្រី ឧបករណ៍ស្បៃមុង ។ល។

**ឧបករណ៍នេសាទ ទូក និងកាណូតរបស់សមាជិកសហគមន៍ដែលប្រើប្រាស់ក្នុងសហគមន៍មានដូចជា៖**

| ល.រ | ឧបករណ៍នេសាទ | ឯកតា | ប្រវែង/ទំហំ/គ្រួសារ | ចំនួន (គ្រួសារ) | រដូវនេសាទ |
|---|---|---|---|---|---|

| | | | | | |
|---|---|---|---|---|---|
| | មងអួស | គ្រឿង | ៦០ម x ៣ម | ០២ | ពេញមួយឆ្នាំ |
| | សន្ទូចរនង | ផ្លែ | ១.៥០០ | ៣៧ | ខែកញ្ញា ដល់ ខែមករា |
| | លបញ្ញឹក | គ្រឿង | ១០ | ៣៦ | ខែសីហា ដល់ ខែកុម្ភៈ |
| | សំណាញ់ | គ្រឿង | ១២ | ២៣ | ខែមករា ដល់ ខែឧសភា |
| | លាន់អន្ទង់ | ដើម | ១០០ | ២១ | ខែសីហា ដល់ ខែកុម្ភៈ |
| | លបលួង | គ្រឿង | ២០ - ៤០ | ១៥ | ខែមីនា ដល់ ខែឧសភា |

| ប្រភេទទូក កាណូត | ចំនួន(គ្រឿង) | ចំណុះ(គក្រ) | កំលាំងសេះ |
|---|---|---|---|
| កាណូតម៉ាស៊ីន HYNOTA | ១១៤ | ៣០០- ១.០០០ | ៦ ដល់ ១៨ |
| ទូកអុំ ឬទូកចែវ | ២០ | ២០០ - ៣០០ | |

ឧបករណ៍នេសាទ និងទូក កាណូតរបស់អ្នកមិនមែនជាសមាជិកសហគមន៍ដែលមកពីក្រៅសហគមន៍នេសាទ

| ល.រ | ឧបករណ៍នេសាទ | ឯកតា | ប្រវែង/ទំហំ/គ្រួសារ | ចំនួន(គ្រួសារ) | រដូវនេសាទ |
|---|---|---|---|---|---|
| ១ | មងរាយ | ម៉ែត្រ | ៣០០ | ៨៣ | ខែកញ្ញា ដល់ ខែមីនា |
| ២ | សន្ទូចរនង | ផ្លែ | ៣០០ | ៦០ | ខែមករា ដល់ ខែធ្នូ |
| ៣ | ទ្រូកំពឹស | ទ្រូ | ២០ | ២០ | ខែវិច្ឆិកា ដល់ ខែកុម្ភៈ |
| ៣ | លបញ្ញឹក | គ្រឿង | ១០ | ២០នាក់ | ខែវិច្ឆិកា ដល់ ខែកុម្ភៈ |
| ៤ | លាន់អន្ទង់ | ដើម | ៥ | ១២នាក់ | ខែសីហា ដល់ ខែមករា |

| ប្រភេទទូក កាណូត | ចំនួន(គ្រឿង) | ចំណុះ(គក្រ) | កំលាំងសេះ |
|---|---|---|---|
| កាណូត (ម៉ាស៊ីនសាំង) | ៣២៧ | ៥០០ | ៨ |
| ទូកអុំ ឬទូកចែវ | ៣០ | ២០០ - ៣០០ | |

ជាទូទៅនៅរដូវប្រាំង ប្រជានេសាទខាងក្រៅសហគមន៍ ច្រើនធ្វើដំណើរមកធ្វើនេសាទក្នុងដែននេសាទសហគមន៍ ដោយមធ្យោបាយផ្សេងៗ ដូចមានក្នុងតារាងខាងក្រោម៖

| មធ្យោបាយធ្វើដំណើរ | ចំនួន(គ្រឿង) | ចំណុះ(គក្រ) | ផ្សេងៗ |
|---|---|---|---|
| ម៉ូតូ | ៥០ | ១០០ | |
| គោយន្ត | ០៣ | ៥០០ | |

## គ. ការប៉ាន់ប្រមាណផលនេសាទចាប់បានប្រចាំឆ្នាំ

| ប្រភេទផលនេសាទ | បរិមាណផលនេសាទចាប់បានគិតជាមធ្យមប្រចាំគ្រួសារ (គិតជាគក្រ) | | |
|---|---|---|---|
| | រដូវប្រាំង | រដូវវស្សា | សរុបប្រចាំឆ្នាំ |
| ត្រីគ្រប់ប្រភេទ | ៧៣០ | ៨២០ | ១.៥៥០ |
| អន្ទង់ | ១២០ | ១៤០ | ២៦០ |
| ក្តាម ខ្យង | ៣២៥ | ៤៣៤ | ៧៥៩ |
| សរុប | ១.១៧៥ | ១.៣៩៤ | ២.៥៦៩ |

## ៥. ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

### ក. ទស្សនៈវិស័យ

ប្រជាពលរដ្ឋក្នុងសហគមន៍ផ្ទាល់ដាច់ មានចំណេះដឹង និងបទពិសោធន៍ខ្ពស់ អំពីការគ្រប់គ្រងធនធាន តាមបែបសហគមន៍ ដោយមានការចូលរួមយ៉ាងសកម្មក្នុងការងារអភិរក្ស និងការប្រើប្រាស់ធនធានធម្មជាតិក្នុងសហគមន៍ ប្រកបដោយសមធម៌ និងធានានិរន្តរភាព ដែលមានទស្សនៈវិស័យ ជារួមមួយបានជួយកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋក្នុងសហគមន៍ ។

### ខ. គោលបំណង

ចូលរួមគ្រប់គ្រងដែននេសាទទឹកសាប ដែលជាកន្លែងនេសាទគ្រួសារ ទុកសម្រាប់ប្រជាពលរដ្ឋធ្វើនេសាទជាលក្ខណៈប្រពៃណី ឬសហគមន៍ធ្វើនេសាទ ទំនាបលិចទឹកក្នុងរដូវទឹកជំនោរឡើង នាទីព្រៃលិចទឹក និងកន្លែងអន្លង់អភិរក្ស ។

ចូលរួមគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តរភាព និងធានាការបែងចែកផលប្រយោជន៍ធនធានជលផលជូនប្រជាពលរដ្ឋខ្មែរប្រកបដោយសមធម៌ ។

ធ្វើឲ្យប្រសើរឡើងនូវកម្រិតជីវភាពរបស់សមាជិកសហគមន៍នេសាទ តាមរយៈការអភិវឌ្ឍន៍ចម្រុះ ដោយមានការចូលរួម ។

ដើម្បីឲ្យប្រជាពលរដ្ឋខ្មែរបានយល់ច្បាស់ ហើយនឹងឈានទៅចាត់ទុកថាខ្លួនជាម្ចាស់ផ្ទាល់ លើការគ្រប់គ្រងធនធានធម្មជាតិក្នុងសហគមន៍ ។

### គ. ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

### គ.១. ផែនការប្រើប្រាស់ឧបករណ៍នេសាទ

### គោលបំណង

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមន៍ គឺបានរៀបចំឡើងដោយគិតគូរអំពីទំហំនៃដែននេសាទ ប្រភេទ ទំហំ ប្រវែង ចំនួនឧបករណ៍នេសាទ ចំនួនអ្នកនេសាទ និង រដូវនេសាទ និងការប៉ាន់ប្រមាណផលស្តុក ដែលមាននៅក្នុងដែននេសាទ ដោយធ្វើយ៉ាងណាមិនឲ្យការធ្វើនេសាទលើសពីតម្រូវការធនធានជលផល ដែលមានក្នុងកន្លែងសហគមន៍នេសាទ ។

**ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទត្រូវបានរៀបចំឡើងដូចខាងក្រោម៖**

| ល.រ | ឧបករណ៍នេសាទ | ប្រវែង/ទំហំ/គ្រួសារ | ចំនួន(គ្រួសារ) | រដូវនេសាទ |
|---|---|---|---|---|
| ១ | មងរាយ | ៥០០ម៉ែត្រ (១,៥០សម) | ៤០ នាក់ | ខែ ០១ ដល់ ខែ ១២ |
| ២ | សន្ទូចរនង | ៧០០ផ្លែ | ៥០ នាក់ | ខែ ០៦ ដល់ ខែ ១២ |
| ៣ | មងហ៊ុំ | ៣០ម៉ែត្រ (១,៥០សម) | ៥ នាក់ | ខែ ០៦ ដល់ ខែ ១២ |
| ៤ | លប | ០៥ គ្រឿង | ៣ នាក់ | ខែ ០៦ ដល់ ខែ ១២ |
| ៥ | លបបង្កប់ | ២០គ្រឿង | ៥ នាក់ | ខែ ០២ ដល់ ខែ ០៦ |
| ៦ | សំណាញ់ | ០៤ ម៉ែត្រ | ៩០ នាក់ | ខែ ០១ ដល់ ខែ ១២ |
| ៧ | ឡើ | ២០គ្រឿង (០,៥សម) | ១៥ នាក់ | ខែ ០១ ដល់ ខែ ១២ |
| ៨ | លាន់ | ៥០លាន់ (បំពង់ឬស្សី) | ១០ នាក់ | ខែ ០១ ដល់ ខែ ១២ |
| ៩ | លបព្រៀង | ២០គ្រឿង (១,៥សម) | ១៣ នាក់ | ខែ ០១ ដល់ ខែ ១២ |

| | | | | |
|---|---|---|---|---|
| ១០ | មងព្រយុង | ២០ម៉ែត្រ (១,៥សម) | ២ នាក់ | ខែ ០១ ដល់ ខែ ១២ |
| ១១ | មងអូសដៃ | ៤០ម៉ែត្រ (១,៥សម) | ៥ នាក់ | ខែ ០៦ ដល់ ខែ ១២ |
| ១២ | ទ្រូ | ២៥ គ្រឿង | ១០ នាក់ | ខែ ០១ ដល់ ខែ ១២ |

## គ.២. ផែនការកែលំអដែននេសាទ

ផែនការកែលំអដែននេសាទសហគមន៍នេសាទថ្នល់ដាច់ គឺជាការងារមួយដែលត្រូវទាមទារមានការគាំទ្រផ្នែកបច្ចេកទេស និងថវិកា និងប្រើប្រាស់ពេលវេលាធ្វើការសិក្សា ពិគ្រោះយោបល់មួយច្បាស់លាស់ ពីព្រោះថាការកែលំអដែននេសាទសហគមន៍នេះ មានផលប៉ះពាល់ ជាមួយត្រីមេពូជ និងពពួកវារីសត្វគ្រប់ប្រភេទ នៅក្នុងដែននេសាទនោះ ។ ករណីនេះក្នុងកិច្ចប្រជុំរវាងគណៈកម្មការ សមាជិកសហគមន៍នេសាទ អាជ្ញាធរមូលដ្ឋាន និងក្រុមមន្ត្រីសម្របសម្រួលរដ្ឋបាលជលផលថ្នាក់កណ្ដាល បានពិនិត្យឃើញថា ដែននេសាទនៅក្នុងសហគមន៍នេសាទថ្នល់ដាច់មានសភាពប្រែប្រួលខ្លះៗ ដែលបណ្ដាលមកពីកត្តាមនុស្ស និងកត្តាធម្មជាតិដូចជា នៅតាមបណ្ដោយព្រែកដែលធ្វើចរាចរទៅ មករាល់ថ្ងៃនោះ ទទួលរងនូវការរីងរ៉ាក់ ដោយអន្លើៗ ដែលបណ្ដាលមកពីការដាក់សំរាស់ក្នុងព្រែក ការចាក់សំរាមចូល និងការហូរច្រោះដោយសារការកាប់ទន្រ្ទានព្រៃលិចទឹកនៅតាមមាត់ព្រែក ។

**ផែនការកែលំអដែននេសាទរបស់សហគមន៍នេសាទថ្នល់ដាច់ ក្នុងគោលបំណង៖**

-បង្កើនផលត្រី និងវារីសត្វគ្រប់ប្រភេទ និងជួយថែរក្សាលំនឹងបរិស្ថានធម្មជាតិ

-ធ្វើឱ្យសំបូរព្រៃលិចទឹកនៅក្នុងដែននេសាទសហគមន៍

-ទាក់ទាញភ្ញៀវទេសចរណ៍មកកំសាន្ត

**ផែនការកែលំអដែននេសាទ បានរៀបចំដូចមានក្នុងតារាងខាងក្រោម៖**

| **ឈ្មោះដែននេសាទ** | **ផ្ទៃដី** (ហត) | **ផ្ទៃដីត្រូវកែលំអ** (ហត) | **សកម្មភាព** | **ថ្ងៃ ខែ ឆ្នាំ ចាប់ផ្ដើម** | **ថ្ងៃ ខែ ឆ្នាំ បញ្ចប់** |
|---|---|---|---|---|---|
| ត្រពាំងថ្លាត | ២,០០ | ២,០០ | -ការសិក្សា និងពិគ្រោះយោបល់<br>-ការស្ដារត្រពាំង | ២០១៨ | ២០១៩ |

## គ.៣. ផែនការរៀបចំកន្លែងអភិរក្ស

គណៈកម្មការ និងសមាជិកសហគមន៍នេសាទថ្នល់ដាច់ បានមូលមតិគ្នាសម្រេចបង្កើតកន្លែងអភិរក្សចំនួន ០២ កន្លែង ដែលជាកន្លែងមានសក្ដានុពលសម្រាប់អភិរក្សត្រីមេពូជ ។ កន្លែងអភិរក្សត្រូវបានធ្វើការគ្រប់គ្រងបន្ទាប់ពីសហគមន៍នេសាទថ្នល់ដាច់ ត្រូវបានប្រកាសទទួលស្គាល់ដោយក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ ។ ការបង្កើតកន្លែងអភិរក្សក្នុងគោលបំណង៖

-បង្កើនពូជត្រី និងសត្វគ្រប់ប្រភេទ

-ថែរក្សា ការពារនាទីព្រៃលិចទឹក ដែលជាជម្រក និងប្រភពចំណីរបស់ត្រី និងសត្វ

-ផ្ដល់ចំណេះដឹងដល់ប្រជាពលរដ្ឋ ឱ្យចេះស្រឡាញ់ ថែរក្សា ការពារធនធានធម្មជាតិ ជាពិសេសគឺការពារធនធានជលផល បរិស្ថាន និងចូលរួមលុបបំបាត់ការនេសាទខុសច្បាប់

តាមការចុះអង្កេត និងពិនិត្យស្ថានភាពភូមិសាស្ត្រជាក់ស្ដែង របស់ក្រុមការងារជាមួយគណៈកម្មការនិងសមាជិកសហគមន៍នេសាទ ហើយបានពិភាក្សាគ្នាយ៉ាងល្អិតល្អន់លើលក្ខណៈវិនិច្ឆ័យ នៃតំបន់អភិរក្សនោះបានបញ្ជាក់

ជា៖ បឹងសំពាន់ និងបឹងចំការឈូក គឺជាកន្លែងសំខាន់បំផុតសម្រាប់ធ្វើការអភិរក្ស ដែលសមាជិកសហគមន៍នេសាទថ្នល់ដាច់ មានសុច្ឆន្ទៈចង់ចូលរួមក្នុងការគ្រប់គ្រងធនធានជលផល ដើម្បីធានាប្រសិទ្ធភាពនៃការគ្រប់គ្រងធនធានជលផល និងជាប្រយោជន៍សម្រាប់តម្រូវការជលត្រីរបស់ប្រជាពលរដ្ឋក្នុងសហគមន៍ ។

កន្លែងអភិរក្សត្រីមេពូជជាកត្តាចាំបាច់ ដែលត្រូវរៀបចំកំណត់ព្រំប្រទល់ បោះបង្គោលស៊ីម៉ង់ត៍ព្រំប្រទល់ ធ្វើផ្ទាំងរូបភាពផ្សព្វផ្សាយ ក្តារខៀនព័ត៌មាន បិទផ្សាយបទបញ្ញត្តិផ្សេងៗ សម្រាប់កន្លែងអភិរក្ស និងសាងសង់រោងយាមសម្រាប់ក្រុមល្បាតបំពេញការងារ មធ្យោបាយ និងសម្ភារៈបរិក្ខារផ្សេងៗ ទៀត ។

**ផែនការរៀបចំកន្លែងអភិរក្ស មានដូចក្នុងតារាងខាងក្រោម៖**

| ឈ្មោះ/ ទីតាំង | ផ្ទៃដី (ហិត) | ប្រភេទ នៃការអភិរក្ស | សកម្មភាព | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|
| បឹងចំការឈូក | ១០៧ | -ប្រភេទត្រីសំខាន់ៗ<br>-ប្រភេទសត្វស្លាប<br>-ពពួកសត្វល្មូន<br>-នាទីព្រៃលិចទឹក | -សិក្សាពីទីតាំងភូមិសាស្ត្រ<br>-ផ្សព្វផ្សាយដល់ប្រជាពលរដ្ឋ<br>-បោះបង្គោលចំនួន ០៦កញ្ចុម<br>-រៀបចំបង្គោលក្រាក់ចំនួន ៦០ ដើម<br>-ធ្វើប៉ាណូផ្សព្វផ្សាយ<br>-ចុះល្បាតជាប្រចាំ | ២០១៨ | ២០១៩ |
| បឹងសំពាន់ | ២៣ | -ប្រភេទត្រីសំខាន់ៗ<br>-ប្រភេទសត្វស្លាប<br>-នាទីព្រៃលិចទឹក | -សិក្សាពីទីតាំងភូមិសាស្ត្រ<br>-ផ្សព្វផ្សាយដល់ប្រជាពលរដ្ឋ<br>-ធ្វើប៉ាណូផ្សព្វផ្សាយ<br>-បោះបង្គោលចំនួន ០៤កញ្ចុម<br>-រៀបចំជម្រកសិប្បនិម្មិត ចំនួន០៥ កន្លែង<br>-ចុះល្បាតជាប្រចាំ | ២០១៨ | ២០១៩ |

## គ.៤. ផែនការគ្រប់គ្រងព្រៃលិចទឹក

សហគមន៍នេសាទថ្នល់ដាច់ មានគ្របដណ្តប់ដោយនាទីព្រៃលិចទឹកដ៏ស្រស់បំព្រង ដែលបានផ្តល់នូវសក្តានុពល និងសារៈប្រយោជន៍ជាច្រើនដល់ប្រភេទត្រី ពពួកសត្វល្មូន ប្រភេទសត្វស្លាបទឹក និងវារីសត្វផ្សេងៗទៀត សម្រាប់ជាជម្រករស់នៅ បង្កកំណើតជាកូន និងជាចំណីផងដែរ ។

ផែនការគ្រប់គ្រងនាទីព្រៃលិចទឹកមានគោលបំណង៖

-ថែរក្សា ការពារព្រៃលិចទឹកឱ្យនៅគង់វង្ស សម្រាប់ការប្រើប្រាស់យូរអង្វែង ដល់កូនចៅជំនាន់ក្រោយ

-ទុកជាជម្រកត្រី និងវារីសត្វគ្រប់ប្រភេទ និងជួយថែរក្សាលំនឹងបរិស្ថានធម្មជាតិ ទប់ស្កាត់ការហូរច្រោះទឹករលក និងជារបាំងខ្យល់

-បង្កើនទិន្នផលត្រី និងពពួកសត្វមានជីវិតគ្រប់ប្រភេទឲ្យសំបូរឡើង

គណៈកម្មការ និងសមាជិកសហគមន៍នេសាទថ្នល់ដាច់ បានកំណត់និងបែងចែកនាទីព្រៃលិចទឹកនិងកន្លែងប្រើប្រាស់ព្រៃលិចទឹក ដោយផ្អែកតាមផែនទីធនធានក្នុងសហគមន៍នេសាទ ។ តំបន់ប្រើប្រាស់នាទីព្រៃលិចទឹកត្រូវបានអប់រំ ផ្សព្វផ្សាយ ណែនាំដល់ប្រជាពលរដ្ឋឱ្យចេះកាប់រំលោះមែក ដែលធ្វើយ៉ាងណាមិនឲ្យងាប់ដើម ដើម្បីយកមកប្រើប្រាស់ជាអុសចំអិនអាហារ ។ ការកាប់រំលោះនេះធ្វើជាលក្ខណៈវិលជុំជារៀងរាល់បីឆ្នាំម្តង ដើម្បីទុកឱ្យព្រៃ

មានលទ្ធភាពអាចដុះលូតលាស់ឡើងវិញបាន ។

ដោយសារការយល់ដឹងពីសារៈសំខាន់នៃនាទីព្រៃលិចទឹកនេះហើយ ទើបប្រជាពលរដ្ឋក្នុងសហគមន៍មានការចូលរួមចំណែកយ៉ាងសកម្មក្នុងការគ្រប់គ្រងធនធានជលផលឱ្យប្រសើរឡើង ។

ផែនការគ្រប់គ្រងនាទីព្រៃលិចទឹកក្នុងសហគមន៍នេសាទថ្នល់ដាច់ មានដូចខាងក្រោម:

| ឈ្មោះ/ទីតាំង | ផ្ទៃដី (ហត) | ប្រភេទកូនឈើត្រូវការពារ | សកម្មភាព | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|
| ការអភិរក្សនាទីព្រៃលិចទឹក (ទំនាបថ្លាតុ និងថ្នល់ដាច់) | ៩២០ | ដើមរាំង ថ្លោល គួរ និងច្រកែង ត្រស់ | -ផ្សព្វផ្សាយពីផលប្រយោជន៍នៃការគ្រប់គ្រងព្រៃលិចទឹក<br>-ដាក់ស្លាកសញ្ញាការពារ<br>-ការថែរក្សា និងការពារ | ២០១៨ | ២០២០ |

## គ.៥. ផែនការអភិវឌ្ឍន៍វារីវប្បកម្ម

ក្រៅពីនេសាទត្រី ការចិញ្ចឹមត្រីជាមុខរបរចំបងរបស់ប្រជានេសាទនៅក្នុងសហគមន៍ថ្នល់ដាច់ ។ ជាទូទៅប្រជាពលរដ្ឋក្នុងសហគមន៍នេសាទនេះ ភាគច្រើនមានចិញ្ចឹមត្រីនៅក្នុងស្រះ និងបែ ពីព្រោះសហគមន៍នេះស្ថិតក្បែរបឹងទន្លេសាប ដែលមានប្រភពទឹកពីព្រែកតភ្ជាប់ជាមួយបឹងទន្លេសាប ។ ប្រភេទត្រីចិញ្ចឹមមានដូចជា៖ ត្រីរ៉ស់ ត្រីប្រា ត្រីឆ្ពិន ត្រីទីឡាព្យា និងត្រីអណ្តែង ។ល។ ការចិញ្ចឹមត្រីជាទម្លាប់របស់ប្រជាពលរដ្ឋកម្ពុជាជាយូរឆ្នាំមកហើយ ដោយអ្នកខ្លះចាប់បានពូជត្រីពីធម្មជាតិ អ្នកខ្លះទៀតចិញ្ចឹមដូចជាលក្ខណៈប្រស់ឬចិញ្ចឹមបំប៉នឲ្យមានទំហំសមស្របសម្រាប់តម្រូវការទីផ្សារ ។

ការចិញ្ចឹមត្រីជាទិសដៅដ៏សំខាន់របស់វិស័យជលផលក្នុងការបង្កើនត្រីសាច់សម្រាប់ហូបចុក របស់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន និងសម្រាប់នាំចេញទៅទីផ្សារក្រៅប្រទេស ដើម្បីរួមចំណែកជួយលើកស្ទួយសេដ្ឋកិច្ចគ្រួសារឱ្យមានការរីកចំរើន ។

**ការអភិវឌ្ឍន៍វារីវប្បកម្មរបស់សហគមន៍នេសាទថ្នល់ដាច់ក្នុងគោលបំណង ៖**

-បង្កើនត្រីសាច់សម្រាប់ហូបចុក របស់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន

-បង្កើនប្រាក់ចំណូលដែលជួយលើកស្ទួយសេដ្ឋកិច្ចគ្រួសារ

-កាត់បន្ថយសម្ពាធ នៃការធ្វើអាជីវកម្មលើធនធានជលផលហួសកំរិត

ឆ្លើយតបទៅនឹងការពង្រីកការអភិវឌ្ឍន៍វារីវប្បកម្ម នេះ គណៈកម្មការ និងសមាជិកសហគមន៍នេសាទថ្នល់ដាច់បានរៀបចំផែនការអភិវឌ្ឍន៍ ការចិញ្ចឹមត្រីមានដូចខាងក្រោម៖

| ប្រភេទវារីវប្បកម្ម | សកម្មភាព | ចំនួន (គ្រួសារ) | ប្រភេទកូនត្រីពូជ | បរិមាណកូនត្រីពូជ (ក្បាល) | ខែ/ ឆ្នាំ | |
|---|---|---|---|---|---|---|
| | | | | | ចាប់ផ្តើម | ប្រមូលផល |
| ការចិញ្ចឹមត្រីក្នុងស្រះជាលក្ខណៈគ្រួសារ | -ជ្រើសរើសកសិករស្ម័គ្រចិត្ត<br>-វគ្គបណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមត្រី<br>-ការជីក ស្តារស្រះ<br>-ផ្តល់កូនត្រីពូជ<br>-ការតាមដាន ត្រួតពិនិត្យ | ១០ | ត្រីប្រា<br>ត្រីឆ្ពិន<br>ត្រីទីឡាព្យា | ៨.០០០<br>៤.០០០<br>២.០០០ | ២០១៩ | ២០១៩ |

### គ.៦. ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍

គណៈកម្មការសហគមន៍នេសាទថ្នល់ដាច់ មានតួនាទីយ៉ាងសំខាន់ក្នុងការស្វែងរកថវិកាចំណូលពីប្រភពផ្សេងៗដូចជា៖ ភាគទានពីសមាជិកសហគមន៍ អ្នកនេសាទមកពីខាងក្រៅ អង្គការដៃគូអភិវឌ្ឍន៍ សប្បុរសជន ក្រុមប្រឹក្សាឃុំ ភៀវទេសចរណ៍ និងការធ្វើទស្សនៈកិច្ចរបស់ភ្ញៀវមកក្នុងសហគមន៍នេសាទ ។

ផែនការស្វែងរកថវិការសម្រាប់ទ្រទ្រង់សហគមន៍ មានក្នុងតារាងខាងក្រោម៖

| ប្រភេទចំណូល | សកម្មភាព | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ | អ្នកទទួលខុសត្រូវ |
|---|---|---|---|---|
| -ភាគទានប្រចាំឆ្នាំពីសមាជិកសហគមន៍<br>-ភាគទានពីអ្នកនេសាទខាងក្រៅ<br>-ជំនួយសប្បុរសជនអង្គការដៃគូ និងក្រុមប្រឹក្សាឃុំ<br>-ភ្ញៀវទេសចរណ៍ | -ផ្សព្វផ្សាយបន្ថែមពីលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុង<br>-ផ្សព្វផ្សាយ អំពីថវិកាភាគទាន<br>-ចេញប័ណ្ណភាគទាន<br>-លើកសំណើសុំថវិកា<br>-បង្កើនមុខរបរចិញ្ចឹមជីវិត<br>-ថែរក្សាធនធានជលផលអភិរក្ស<br>-បង្ក្រាបបទល្មើស<br>-ជួយសង្គ្រោះសមាជិកងាយរងគ្រោះ | ២០១៨ | ២០២០ | គណៈកម្មការសហគមន៍ |

### គ.៧. ផែនការសកម្មភាពផ្សេងៗ សមាហរណកម្មជាមួយផែនការអភិវឌ្ឍន៍ឃុំ

| សកម្មភាព | ចំនួន | ថវិកាចំណាយ | ចាប់ផ្តើម | បញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|
| ១. ពង្រឹងសហគមន៍នេសាទ | | | | | |
| ដាក់ជម្រកសិប្បនិម្មិតបឹងអភិរក្ស | ១ | ៤.០០០.០០០ | ២០១៩ | ២០១៩ | |
| សង់រោងយាមនៅបឹងអភិរក្ស | ១ | ១៦.០០០.០០០ | ២០១៩ | ២០១៩ | |
| ដាក់ស្លាកសញ្ញា | ២ | ១.៦០០.០០០ | ២០១៩ | ២០១៩ | |
| ធ្វើក្តារខៀនព័ត៌មាន | ៦ | ២.៥២០.០០០ | ២០១៩ | ២០១៩ | |
| សកម្មភាពចុះល្បាត (ក្នុង០១ឆ្នាំ) | ១២ដង | ៧.២០០.០០០ | ២០១៨ | ២០២០ | |
| បណ្តុះបណ្តាលគណៈកម្មការសហគមន៍ និងទស្សនៈកិច្ច | ៣ | ៤.០០០.០០០ | ២០១៩ | ២០១៩ | |
| ផ្សព្វផ្សាយផែនការគ្រប់គ្រង និងច្បាប់ជលផល | ៦ | ១.២០០.០០០ | ២០១៩ | ២០១៩ | |
| ទិញសម្ភារះរដ្ឋបាល | ៣ ឆ្នាំ | ៦០០.០០០ | ២០២០ | ២០២០ | |

| | | | | | |
|---|---|---|---|---|---|
| ទិញកាណូត | ១ | ៦.០០០.០០០ | ២០២០ | ២០២០ | |
| ទិញទូក | ២ | ២.៤២០.០០០ | ២០២០ | ២០២០ | |
| ទិញវិទ្យុទាក់ទង | ៥ | ២.៤២០.០០០ | ២០១៨ | ២០១៩ | |
| **២. សហគ្រាសខ្នាតតូច** | | | | | |
| គាំទ្របច្ចេកទេស និងបង្កើនគុណភាពកែច្នៃផលនេសាទ | ៤ គ្រួសារ | ១៦.០០០.០០០ | ២០១៨ | ២០១៩ | |
| លើកកម្ពស់កែច្នៃផលិតផលកំប្លោក | ១០គ្រួសារ | ៨.០០០.០០០ | ២០១៨ | ២០១៨ | |
| បង្កើនមុខរបរចិញ្ចឹមជីវិត តាមរយៈឥណទានខ្នាតតូច | ២៥០នាក់ | ១០០.០០០.០០០ | ២០១៨ | ២០១៩ | |
| **៣. សកម្មភាពអភិវឌ្ឍន៍ភូមិ** | | | | | |
| ជីកស្រះទឹក | ២ | ៨០.០០០.០០០ | ២០១៩ | ២០១៩ | ត្រាវគៀត គោកឬស្សីត្បូង |
| ធ្វើរបងស្រះទឹក | ១ | ៨.០០០.០០០ | ២០១៩ | ២០១៩ | ត្រាវគៀត |
| សង់សាលារៀន | ៣បន្ទប់ | ៦០.០០០.០០០ | ២០១៩ | ២០១៩ | ថ្នល់ដាច់ |
| ក្រាលគ្រួសក្រហមផ្លូវ ០៣ ខ្សែ | ៦.០០០ម | ៧២.០០០.០០០ | ២០១៩ | ២០១៩ | ត្រាវគៀត, ស្រម៉ធំ, គោកឬស្សីត្បូង |
| ធ្វើរបាំងការពារទ្វារលូទឹក ទំនប់ ៧៨ | ៤ | ៦០.០០០.០០០ | ២០១៩ | ២០១៩ | គោកឬស្សីត្បូង, ជើង, ត្រាវគៀត ថ្នល់ដាច់ |
| កែលម្អផ្សារបឹងខ្យង | | ២៤.០០០.០០០ | ២០១៩ | ២០១៩ | គោកឬស្សីត្បូង |
| អគ្គីសនីពន្លឺព្រះអាទិត្យ | ៥ | ៣៦.០០០.០០០ | ២០១៩ | ២០២០ | ៥ភូមិ |
| ស្ពានស្រះទឹក ០២ | ៥០ x៣០ ៨០ x៧០ | ១២.០០០.០០០ | ២០១៩ | ២០២០ | ស្រម៉ធំ គោកឬស្សីត្បូង |
| ទិញម៉ាស៊ីនបូមទឹកខ្នាតធំ | ១គីឡូ | ១២.០០០.០០០ | ២០១៩ | ២០២០ | ៥ ភូមិ |
| វគ្គបណ្តុះបណ្តាលវិជ្ជាជីវៈ | ២៥នាក់ | ១០០.០០០.០០០ | ២០២០ | ២០២០ | ៥ ភូមិ |
| ឥណទានគោមេពូជ | ៩ក្បាល | ១៤.៤០០.០០០ | ២០២០ | ២០២០ | ៣ ភូមិ |
| បង្កើតធនាគារស្រូវ | ១ | ៤៤.៨០០.០០០ | ២០២០ | ២០២០ | ត្រាវគៀត ថ្នល់ដាច់ |
| ទិញដីចែកប្រជាជនក្រីក្រ | ៥ហត | ១០០.០០០.០០០ | ២០២០ | ២០២០ | ៥ ភូមិ |

| | | | | | |
|---|---|---|---|---|---|
| ជួសជុលផ្លូវចាស់ ០១ខ្សែ | ៣០០ម | ៤៨.០០០.០០០ | ២០២០ | ២០២០ | គោកឬស្សីត្បូង |

**ឃ.យុទ្ធសាស្ត្រ**

នៅសហគមន៍នេសាទថ្នល់ដាច់ ត្រូវបានរៀបចំយុទ្ធសាស្ត្រមួយចំនួន ដើម្បីឲ្យការអនុវត្តផែនការសកម្មភាពទទួលបានជោគជ័យ ហើយយុទ្ធសាស្ត្រទាំងនោះមានដូចខាងក្រោម៖

-បង្កើតគណៈកម្មការសម្រាប់អនុវត្ត តាមដានត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តន៍ផែនការរួមមាន៖ គណៈកម្មការ ចាស់ទុំ សមាជិកសហគមន៍នេសាទដែលមានបទពិសោធន៍ និងចំណេះដឹងល្អៗ ជាពិសេសអំពីបញ្ហានេសាទ ។

-ស្នើសុំជំនួយបច្ចេកទេសពីរដ្ឋបាលជលផលមានសមត្ថកិច្ចដើម្បីជួយផ្តល់យោបល់ចំពោះផែនការណាដែលទាក់ទងនឹងបច្ចេកទេសជលផល ដូចជាៈ ការធ្វើផែនការអភិវឌ្ឍន៍កន្លែងអភិរក្សត្រីមេពូជ ការរៀបចំកន្លែងអភិរក្សព្រៃលិចទឹក កន្លែងអភិរក្សជីវៈចម្រុះ ការស្តារព្រៃក ការកំណត់ប្រភេទឧបករណ៍នេសាទ ការចិញ្ចឹមត្រី ការរកប្រភពថវិកាទ្រទ្រង់ជាដើម ។

-ទំនាក់ទំនងជាមួយស្ថាប័នជំនាញពាក់ព័ន្ធ អង្គការនានា គម្រោងការ និងម្ចាស់ជំនួយនានា ដើម្បីទទួលបានការឧបត្ថម្ភគាំទ្រ និងថវិកាសម្រាប់ដំណើរការអនុវត្តផែនការ ។

-រៀបចំកម្មវិធីអនុវត្តផែនការ តាមដំណាក់កាលនីមួយៗដោយជាក់លាក់ ។

-ទាក់ទងជាមួយរដ្ឋបាលជលផល ដើម្បីសុំការគាំទ្រថវិកា និងជួយរកដៃគូ សម្រាប់ទ្រទ្រង់ផែនការគ្រប់គ្រងសហគមន៍នេសាទ ។

-ផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ដល់សមាជិកសហគមន៍នេសាទ និងអ្នកពាក់ព័ន្ធសំខាន់ៗ ដើម្បីជម្រុញការចូលរួម និងគាំទ្រដល់ការអនុវត្តផែនការគ្រប់គ្រងនេះ ។

-កៀងគរការចូលរួមចំណែករបស់សមាជិកសហគមន៍នេសាទ ។

-រៀបចំវិធានការចំពោះអ្នកនេសាទមកពីខាងក្រៅសហគមន៍ ។

-ពង្រឹងសមត្ថភាពបច្ចេកទេស និងដឹកនាំ គ្រប់គ្រងរបស់គណៈកម្មការសហគមន៍នេសាទ ។

-ចងក្រងក្រុមអ្នកនេសាទទៅតាមប្រភេទឧបករណ៍នេសាទ ដើម្បីចូលរួមអនុវត្តផែនការ ។

-បញ្ចូលផែនការគ្រប់គ្រងសហគមន៍នេសាទទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ ។

## តារាងសង្ខេបផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ថ្លល់ដាច់ រយៈពេល ០៣ ឆ្នាំ ( ២០១៨ ដល់ ២០២០)

| ប្រភេទផែនការ | សកម្មភាព | លទ្ធផលរំពឹងទុក | ការប៉ាន់ស្មានចំណាយ | ប្រភពជំនួយ | ពេលផ្តើម | ពេលបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| ១.ការប្រើប្រាស់ឧបករណ៍នេសាទ | -ផ្សព្វផ្សាយបទបញ្ញាផ្ទៃក្នុង និងលក្ខន្តិកៈសហគមន៍ | -សមាជិកចំនួន ៨០%មានការយល់ដឹង និងចូលរួមអនុវត្ត | ១.២០០.០០០ | -ជំនួយអង្គការនិងសប្បុរសជននានា<br>- ថវិកាបដិភាគរបស់សហគមន៍<br>- រាជរដ្ឋាភិបាល | ២០១៨ | ២០២០ | |
| ២.ការកែលំអដែននេសាទ | -ស្តារត្រពាំងស្លាតផ្ទៃដី ០២ ហត<br>-ដាក់ស្លាកសញ្ញា០២ដើម | -ងាយស្រួលធ្វើចរាចរណ៍ទៅមក | ១០.០០០.០០០ | -ជំនួយអង្គការនិងសប្បុរសជននានា<br>- ថវិកាអភិវឌ្ឍន៍ឃុំ<br>- ថវិកាបដិភាគរបស់សហគមន៍ | ២០១៨ | ២០២០ | |
| ៣.ការកំណត់និងរៀបចំតំបន់អភិរក្ស | -រៀបចំបឹងអភិរក្សត្រីមេពូជ បឹងចំការឈូក ១០៧ ហ.ត និងបឹងសំពាន់ ២៣ ហត | -មានទីជ្រកសម្រាប់ត្រីជ្រក ពងកូន | ២០.០០០.០០០ | -ជំនួយអង្គការនិងសប្បុរសជននានា<br>-រាជរដ្ឋាភិបាល | ២០១៨ | ២០២០ | |
| ៤.ផែនការគ្រប់គ្រងព្រៃលិចទឹក | -អប់រំ ផ្សព្វផ្សាយ<br>-កំណត់នាទីព្រៃលិចទឹក ទំនាបថ្លាត និងថ្លល់ដាច់ ផ្ទៃដី ៩២០ ហត<br>-យាមល្បាតជាប្រចាំ | -ប្រជាពលរដ្ឋមានការយល់ដឹង និងចូលរួមការពារ<br>-បរិមាណព្រៃលិចទឹកកើនឡើង | ១០.៤០០.០០០ | -ជំនួយអង្គការនិងសប្បុរសជននានា<br>-ថវិកាបដិភាគរបស់សហគមន៍<br>- រាជរដ្ឋាភិបាល | ២០១៨ | ២០២០ | |
| ៥.ផែនការអភិវឌ្ឍន៍វារីវប្បកម្ម | ផ្សព្វផ្សាយពីការចិញ្ចឹមត្រីក្នុងស្រះចំនួន១០គ្រួសារ | -ជីវភាពប្រជាពលរដ្ឋប្រសើរឡើង | ៨.០០០.០០០ | -ជំនួយអង្គការនិងសប្បុរសជននានា<br>-ថវិកាបដិភាគរបស់សហគមន៍ | ២០១៩ | ២០១៩ | |
| ៦.ផែនការរកប្រាក់ចំណូលសហគមន៍ | -ប្រមូលថវិកាពីសមាជិកភាពនិងភាគទានប្រចាំឆ្នាំ<br>-ទុនបង្វិល<br>-ស្វែងរកជំនួយបន្ថែមពីអង្គការនិងសប្បុរសជន | -ប្រជាពលរដ្ឋមានការយល់ដឹងនិងចូលរួមភាគទាន<br>-មានថវិកាសម្រាប់អភិវឌ្ឍន៍សហគមន៍ | ៣០.០០០.០០០ | -ជំនួយអង្គការនិងសប្បុរសជននានា<br>-ថវិកាបដិភាគរបស់សហគមន៍<br>- រាជរដ្ឋាភិបាល | ២០១៨ | ២០២០ | |
| សរុប | | | ៧៩.៦០០.០០០ | | | | |

**ផែនការកម្មវិធីអភិវឌ្ឍន៍ផ្សេងៗសម្រាប់សមាហរណកម្មជាមួយភូមិ ឃុំ រយៈពេល ៣ ឆ្នាំ**

| ឈ្មោះកម្មវិធី | អង្គភាពអនុវត្ត | លទ្ធផលរំពឹងទុក | ទីតាំងឬកន្លែងអនុវត្ត | រយៈពេលអនុវត្ត | | | តម្លៃប៉ាន់ស្មាន | ប្រភពទុន |
|---|---|---|---|---|---|---|---|---|
| | | | | ២០១៨ | ២០១៩ | ២០២០ | | |
| ធ្វើជម្រកសិប្បនិម្មិតតំបន់អភិរក្សត្រីមេពូជ | សហគមន៍, ឃុំ, សង្កាត់ជលផល | ត្រីមានជម្រកពងកូន | ត្រពាំងប្រើស | | ២០១៩ | - | ៤.០០០.០០០ | ថវិកាឃុំ |
| ធ្វើរោងយាមតំបន់អភិរក្សត្រីមេពូជ ១កន្លែង | សហគមន៍, ឃុំ | មានកន្លែងស្នាក់នៅ បំពេញការងារ | ត្រពាំងប្រើស | | ២០១៩ | | ១៦.០០០.០០០ | |
| ដាក់ស្លាកសញ្ញាជម្រកត្រីមេពូជ ២កន្លែង | សហគមន៍, ឃុំ | ប្រជាពលរដ្ឋងាយយល់ និងចូលរួមអភិរក្ស | ត្រពាំងប្រើស | | ២០១៩ | | ១.៦០០.០០០ | |
| ធ្វើក្តារខៀនព័ត៌មាន ៦ កន្លែង | សហគមន៍, ឃុំ | ប្រជាពលរដ្ឋទទួលបាននូវព័ត៌មាន | ចំនួន ៥ភូមិ ក្នុងសហគមន៍ | | ២០១៩ | | ២.៥២០.០០០ | |
| ចេញល្បាត ១ខែម្តង | សហគមន៍, សង្កាត់ជលផល | បទល្មើសមានការថយចុះ | ដែនសហគមន៍នេសាទ | ២០១៨ | ២០១៩ | ២០២០ | ៧.២០០.០០០ | |
| បណ្តុះបណ្តាលអំពីការដឹកនាំគ្រប់គ្រងដល់គណៈកម្មការ | សហគមន៍, សង្កាត់ជលផល | ទទួលបានចំណេះដឹងថ្មីៗ | ក្នុងសហគមន៍ | | ២០១៩ | | ៤.០០០.០០០ | |
| ផ្សព្វផ្សាយផែនការគ្រប់គ្រង និងច្បាប់ស្តីពីជលផល | សហគមន៍, សង្កាត់ជលផល | បទល្មើសមានការថយចុះ | ក្នុងនិងក្រៅ សហ គមន៍ | | ២០១៩ | | ១.២០០.០០០ | |
| ទិញសំភារៈរដ្ឋបាល | សហគមន៍ | បំពេញការងារល្អប្រសើរ | សហគមន៍ | | | ២០២០ | ៦០០.០០០ | |
| ទិញកាណូត | សហគមន៍ | មានមធ្យោបាយធ្វើដំណើរ | សហគមន៍ | | | ២០២០ | ៦.០០០.០០០ | |
| ទិញវិទ្យុទាក់ទង | សហគមន៍ | មានភាពងាយស្រួលទាក់ទង | ក្នុង និងក្រៅ សហគមន៍ | | | ២០២០ | ២.៤២០.០០០ | |
| ទិញទូក | សហគមន៍ | មានមធ្យោបាយធ្វើដំណើរ | សហគមន៍ | | | ២០២០ | ២.៤២០.០០០ | |
| ផ្តល់បច្ចេកទេសកែច្នៃផលនេសាទ | សហគមន៍, សង្កាត់ជលផល | ជីវភាពប្រជាពលរដ្ឋមានការរីកចម្រើន | ក្នុងនិងក្រៅ សហគមន៍ | ២០១៨ | ២០១៩ | | ១៦.០០០.០០០ | |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| លើកកម្ពស់ការកែច្នៃ ផលិតផលពីកំប្លោក | សហគមន៍ | ជីវភាពប្រសើរឡើង | សហគមន៍ | ២០១៨ | | | ៨.០០០.០០០ | |
| បង្កើនមុខរបរតាមរយៈឥណទានខ្នាតតូច | សហគមន៍ | ជីវភាពប្រសើរឡើង | សហគមន៍ | ២០១៨ | ២០១៩ | | ១០០.០០០.០០០ | |
| ជីកស្រះទឹកថ្មី ២កន្លែង | សហគមន៍, ភូមិ, ឃុំ | មានទឹកប្រើប្រាស់គ្រប់គ្រាន់ | សហគមន៍ | | ២០១៩ | - | ៨០.០០០.០០០ | |
| ធ្វើរបងស្រះទឹក ១កន្លែង | សហគមន៍, ភូមិ, ឃុំ | មានទឹកប្រើប្រាស់គ្រប់គ្រាន់ | សហគមន៍ | | ២០១៩ | | ៨.០០០.០០០ | |
| សង់សាលារៀន១ខ្នង មាន ៣ បន្ទប់ | សហគមន៍, ភូមិ, ឃុំ | មានសាលារៀនគ្រប់គ្រាន់ | សហគមន៍ | | ២០១៩ | | ៦០.០០០.០០០ | |
| ក្រាលគ្រួសក្រហមផ្លូវ ៣ខ្សែ | សហគមន៍, ភូមិ, ឃុំ | ងាយស្រួលធ្វើដំណើរ | សហគមន៍ | | ២០១៩ | | ៧២.០០០.០០០ | |
| ធ្វើរបាំងការពារទ្វារលូទឹកទំនប់ ៧៨ | សហគមន៍, ភូមិ, ឃុំ | ជៀសវាងគ្រោះថ្នាក់ផ្សេងៗ | សហគមន៍ | | ២០១៩ | | ៦០.០០០.០០០ | |
| កែលម្អផ្សារបឹងខ្យង | សហគមន៍, ភូមិ, ឃុំ | មានបរិស្ថានជុំវិញល្អ | សហគមន៍ | | ២០១៩ | | ២៤.០០០.០០០ | |
| ដាក់អគ្គីសនីពន្លឺព្រះអាទិត្យ ៥ ភូមិ | សហគមន៍, ភូមិ, ឃុំ | មានអគ្គីសនីពន្លឺព្រះអាទិត្យ | សហគមន៍ | | | ២០២០ | ៣៦.០០០.០០០ | |
| ស្ដារស្រះទឹក ២កន្លែង | សហគមន៍, ភូមិ, ឃុំ | មានទឹកប្រើ | សហគមន៍ | | ២០១៩ | ២០២០ | ១២.០០០.០០០ | |
| ទិញម៉ាស៊ីនបូមទឹក | សហគមន៍, ភូមិ, ឃុំ | មានទឹកប្រើ | សហគមន៍ | | ២០១៩ | ២០២០ | ១២.០០០.០០០ | |
| បណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈ | សហគមន៍, ភូមិ, ឃុំ | មានមុខរបរថ្មី | សហគមន៍ | | | ២០២០ | ១០០.០០០.០០០ | |
| ឥណទានគោមេពូជ | សហគមន៍, ភូមិ, ឃុំ | មានមុខរបរថ្មី | សហគមន៍ | | | ២០២០ | ១៤.៤០០.០០០ | |
| បង្កើតធនាគារស្រូវពូជ | សហគមន៍, ភូមិ, ឃុំ | មានពូជស្រូវ | សហគមន៍ | | | ២០២០ | ៤៤.៨០០.០០០ | |
| ទិញដីចែកប្រជាជនក្រីក្រ | សហគមន៍, ភូមិ, ឃុំ | មានកន្លែងស្នាក់នៅ | សហគមន៍ | | | ២០២០ | ១០០.០០០.០០០ | |
| ជួសជុលផ្លូវ ១ខ្សែ | សហគមន៍, ភូមិ, ឃុំ | មានផ្លូវល្អ | សហគមន៍ | | | ២០២០ | ៤៨.០០០.០០០ | |
| សរុប | | | | | | | ៨៤៣.១៦០.០០០ | |

## តារាងកម្មវិធីការងារ

| សកម្មភាព | កាលបរិច្ឆេទ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ២០១៨ | | | | | | | | | | | | ២០១៩ | | | | | | | | | | | | ២០២០ | | | | | | | | | | | |
| | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ |
| ១.ការប្រើប្រាស់ឧបករណ៍នេសាទ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ១.១. ផ្សព្វផ្សាយបទបញ្ញាផ្ទៃក្នុង | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ២. ការកែលម្អដែននេសាទ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ២.១. បោះបង្គោលព្រំប្រទល់ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ២.២. ដាក់ស្លាកសញ្ញា | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៣.ការកំណត់ និងរៀបចំតំបន់អភិរក្ស | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៣.១. ស្តារជម្រកត្រីមេពូជ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៤. ការគ្រប់គ្រងព្រៃលិចទឹក | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៤.១. បណ្តុះកូនឈើព្រៃលិចទឹក | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៤.២. ដាំព្រៃឡើងវិញ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៤.៣.កំណត់តំបន់ប្រើប្រាស់ប្រចាំឆ្នាំ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៥. អភិវឌ្ឍន៍វារីវប្បកម្ម | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៥.១. ចិញ្ចឹមត្រីតាមស្រះ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៦. ផែនការរកប្រាក់ចំណូល | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៦.១. ភាគទានចូលជាសមាជិក | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៦.២. ភាគទានប្រចាំឆ្នាំ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៦.៣. ទុនបង្វិល | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៦.៤. ជំនួយសប្បុរសជន អង្គការនានា | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |

| ៧.ផែនការផ្សេងៗសម្រាប់សមាហ រណកម្ម |
| --- |
| ៧.១. ដាក់ជម្រកសិប្បនិម្មិត |
| ៧.២. ធ្វើរោងយាមតំបន់ត្រីមេពូជ |
| ៧.៣.ដាក់ស្លាកសញ្ញាជម្រកត្រីមេពូជ |
| ៧.៤. រៀបចំក្តារខៀនព័ត៌មាន |
| ៧.៥. ចេញល្បាត |
| ៧.៦.បណ្តុះបណ្តាលគណៈកម្មការ |
| ៧.៧. ផ្សព្វផ្សាយច្បាប់ជលផល |
| ៧.៨. ទិញកាណូត |
| ៧.៩. ទិញវិទ្យុទាក់ទង |
| ៧.១០. ទិញទូក |
| ៧.១១. គាំទ្របច្ចេកទេស |
| ៧.១២.លើកកម្ពស់ការកែច្នៃកំប្លោក |
| ៧.១៣.បង្កើនមុខរបរតាមរយៈឥណទានខ្នាតតូច |
| ៧.១៤. ជីកស្រះទឹក ០២កន្លែង |
| ៧.១៥.ធ្វើរបងស្រះទឹក០១កន្លែង |
| ៧.១៦.សាងសង់សាលារៀន ០១ខ្នង |
| ៧.១៧. ក្រាលគ្រួសក្រហមផ្លូវ ៣ខ្សែ |
| ៧.១៨. ធ្វើរបាំងការពារទ្វារលូទឹក |
| ៧.១៩.កែលម្អផ្សារបឹងខ្យង |
| ៧.២០.ដាក់អគ្គីសនីពន្លឺព្រះអាទិត្យ |
| ៧.២១.ស្តារស្រះទឹក ០២កន្លែង |

| | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ៧.២២.ទិញម៉ាស៊ីនបូមទឹកខ្នាតធំ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៧.២៣. បណ្តុះបណ្តាលការចិញ្ចឹមត្រី | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៧.២៤. ឥណទានមេគោពូជ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៧.២៥. បង្កើតធនាគារស្រូវ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៧.២៦. ទិញដីចែកប្រជាជនក្រីក្រ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៧.២៧. ជួសជុលផ្លូវ ១ខ្សែ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |

បានឃើញនិងគោរពជូន
លោកនាយខណ្ឌរដ្ឋបាលជលផលសៀមរាប
"ដើម្បីជូនពិនិត្យនិងសម្រួល"
ថ្ងៃ[illegible]ខែផល្គុន ឆ្នាំរកា នព្វស័ក ព.ស២៥៦១
ដំដែក ថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ២០១៨
**នាយផ្នែករដ្ឋបាលជលផលដំដែក**

សាម៉េង

បានឃើញនិងគោរពជូន
លោកនាយផ្នែករដ្ឋបាលជលផលដំដែក
"ដើម្បីជូនពិនិត្យនិងសម្រួល"
ថ្ងៃ[illegible]ខែផល្គុន ឆ្នាំរកា នព្វស័ក ព.ស២៥៦១
សូទ្រនិគម ថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ២០១៨
**នាយសង្កាត់រដ្ឋបាលជលផលសូទ្រនិគម**

**លេខ** [illegible]
បានឃើញនិងគោរពជូន
លោកនាយសង្កាត់រដ្ឋបាលជលផលសូទ្រនិគម
"ដើម្បីជូនពិនិត្យនិងសម្រួល"
ថ្ងៃ[illegible]ខែផល្គុន ឆ្នាំរកា នព្វស័ក ព.ស ២៥៦១
ជានរុន ថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ២០១៨
**មេឃុំជានរុន**

ស៊ឿ ដ

សូមគោរពជូន
លោកមេឃុំ
"ដើម្បីជូនពិនិត្យនិងសម្រួល"
ថ្ងៃ[illegible]ខែផល្គុន ឆ្នាំរកា នព្វស័ក ព.ស២៥៦១
[illegible] ថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ២០១៨
**ប្រធានគណៈកម្មការសហគមន៍នេសាទ**

**លេខ** [illegible]
បានឃើញនិងគោរពជូន
លោកប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
ខេត្តសៀមរាប
"ដើម្បីជូនពិនិត្យនិងសម្រួល"
ថ្ងៃ [illegible] ខែ [illegible] ឆ្នាំ [illegible] ព.ស២៥៦១
សៀមរាប ថ្ងៃទី ២៦(?) ខែ កុម្ភៈ ឆ្នាំ២០១៨
**នាយខណ្ឌរដ្ឋបាលជលផលសៀមរាប**

ព្រឹន សារិន

**លេខ** [illegible]
បានឃើញនិងគោរពជូន
ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា
ប្រធានរដ្ឋបាលជលផល
"ដើម្បីជូនពិនិត្យនិងសម្រេចដោយអនុគ្រោះ"
ថ្ងៃ[illegible] ខែ[illegible] ឆ្នាំ [illegible] ព.ស២៥៦
សៀមរាប ថ្ងៃទី ១៥(?) ខែ [illegible] ឆ្នាំ២០១៨
**ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តសៀមរាប**

ទា គឹមសុទ្ធ

**លេខ** [illegible]
បានឃើញនិងឯកភាព
ថ្ងៃ [illegible] ខែ [illegible] ឆ្នាំ [illegible] ព.ស២៥៦
រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ [illegible] ឆ្នាំ២០១៨
**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា**
**ប្រធានរដ្ឋបាលជលផល**

ស្រេង ជាសាន